# គណៈកម្មការស្តារសម្បទា នៃរដ្ឋ Massachusetts

ការរស់នៅក្នុងសហគមន៍ • ការងារ • លក្ខណៈសម្បត្តិទទួលអត្ថប្រយោជន៍ភាពពិការ

## បង្កើតឱកាសសម្រាប់ឯករាជ្យភាព ក្នុងការរស់នៅ និងការងារ

MRC

គណៈកម្មការស្តារសម្បទា នៃរដ្ឋ Massachusetts

## គណៈកម្មការ ស្តារសម្បទានៃរដ្ឋ Massachusetts គឺនៅទីនេះ ដើម្បីជួយលោកអ្នក។

គណៈកម្មការស្តារសម្បទានៃរដ្ឋ Massachusetts (Massachusetts Rehabilitation Commission, MRC) ជួយជនពិការឲ្យរស់នៅ និងធ្វើការងារដោយឯករាជ្យ។ មានជនពិការជាច្រើននាក់ ក្នុងរដ្ឋ Massachusetts។ នៅ MRC យើងផ្តល់សេវា ធនធាន និងការបណ្តុះបណ្តាល ដើម្បីជួយពួកគេ។ យើងជួយមនុស្សជាច្រើនប្រភេទ។

## តើយើងអាចជួយដោយរបៀបណា?

នៅពេលលោកអ្នកមក MRC បុគ្គលិករបស់យើងនឹងពិភាក្សាជាមួយនឹងលោកអ្នកអំពីជីវិតរស់នៅរបស់លោកអ្នក និងអ្វីខ្លះដែលលោកអ្នកចង់ធ្វើ។ យើងមានបទពិសោធន៍ច្រើន ហើយដឹងវិធីជាច្រើនបែប ដើម្បីជួយលោកអ្នកឲ្យសម្រេចគោលដៅ។ ជាញឹកញាប់ ប្រជាជនមានការភ្ញាក់ផ្អើល ដោយសារតែកិច្ចការគ្រប់យ៉ាង ដែលយើងអាចធ្វើបាន សម្រាប់ពួកគេ។ ពួកគេមិនបានដឹងទេថា MRC អាចជួយបានច្រើនបែបនេះនោះ។

## ការចាប់ផ្តើម គឺងាយស្រួល។

ប្រសិនបើលោកអ្នក ឬជនណាម្នាក់ដែលលោកអ្នកស្គាល់ ចង់មានជីវិតរស់នៅឯករាជ្យ សូមទាក់ទងមក MRC។ យើងមានការិយាល័យនៅទូទាំងរដ្ឋ ដែលមានសុទ្ធតែបុគ្គលិកដែលយកចិត្តទុកដាក់ ដែលត្រៀមខ្លួនរួចជាស្រេច ដើម្បីជួយលោកអ្នក។ លោកអ្នកអាចជ្រាបព័ត៌មានបន្ថែមទៀត ដោយចូលទៅគេហទំព័រ ឬទូរស័ព្ទមកកាន់លេខឥតគិតថ្លៃរបស់យើង។ វិធីណាមួយខាងលើនេះនឹងចាប់ផ្តើមដំណើរការតភ្ជាប់លោកអ្នកទៅនឹងជំនួយដែលលោកអ្នកត្រូវការ។

## ធ្វើការរួមគ្នាដើម្បីជោគជ័យរបស់លោកអ្នក។

ក្នុងពេលឆាប់ៗ លោកអ្នកនឹងធ្វើដំណើរឆ្ពោះទៅជីវិតកាន់តែឯករាជ្យថែមទៀត។ ដោយរួមគ្នា យើងនឹងពិភាក្សាគោលដៅ និងបញ្ជាប្រឈមមុខលោកអ្នក ហើយរៀបចំផែនការដើម្បីជោគជ័យរបស់លោកអ្នក។ ប៉ុន្មានខែទៀត យើងនឹងពិនិត្យមើលវឌ្ឍនភាពរបស់លោកអ្នកជាច្រើនលើកច្រើនសារ ដើម្បីធានាថា លោកអ្នកកំពុងធ្វើដំណើរឆ្ពោះទៅមុខយ៉ាងឆាប់រហ័ស តាមដែលអាចធ្វើទៅបាន។ ប្រសិនបើត្រូវផ្លាស់ប្តូរផែនការរបស់លោកអ្នក យើងនឹងផ្លាស់ប្តូរ។ យើងនៅទីនេះដើម្បីជួយលោកអ្នក ហើយយើងមិនទុកអ្វីមួយផ្អែកលើជោគវាសនានោះទេ។ ការធ្វើការជាមួយយើងគឺជាដៃគូពិតៗ។ លោកអ្នកនឹងមានតួនាទីសំខាន់ក្នុងការសម្រេចវឌ្ឍនភាពឆ្ពោះទៅរកជីវិតកាន់តែឯករាជ្យថែមទៀត។

**www.mass.gov/mrc** **1-800-245-6543**

(ទូរស័ព្ទឥតគិតថ្លៃតែក្នុងរដ្ឋ MA មួយគត់)

# ធ្វើការជាមួយ MRC

## 1

### សេចក្ដីត្រូវការ របស់អ្នកប្រើប្រាស់ ត្រូវបានសម្គាល់

ជាញឹកញាប់ ប្រជាជនទាក់ទងយើង បន្ទាប់ពីសមាជិកគ្រួសារ មិត្តភក្ដិ ឬអ្នកវិជ្ជាជីវៈ បានឲ្យយោបល់ថា យើងអាចជួយពួកគេឲ្យរស់នៅកាន់តែឯករាជ្យថែមទៀត។

## 2

### ការប្រឹក្សា និងព័ត៌មាន

ក្នុងកិច្ចប្រជុំទីមួយរបស់យើង យើងនឹងខិតខំស្វែងយល់ស្ថានការណ៍របស់លោកអ្នក និងស្វែងរកវិធីទាំងអស់ ដែលយើងអាចជួយបាន។

## 3

### បុគ្គលិក របស់ MRC ត្រូវ បានចាត់តាំង

បន្ទាប់ពីយើងបានពិភាក្សាជាមួយនឹងលោកអ្នក យើងនឹងសម្រេចថាតើអ្នកណាក្នុង MRC នឹងធ្វើជាជនត្រូវទាក់ទងចម្បងសម្រាប់លោកអ្នក។ បុគ្គលិកនោះនឹងទទួលបន្ទុកធ្វើឲ្យលោកអ្នកទទួលបានសេវាដែលលោកអ្នកត្រូវការ។

## ចក្ខុវិស័យ និងបេសកកម្ម

**គណៈកម្មការស្តារសម្បទានៃរដ្ឋ Massachusetts (MRC)លើកកំពស់សមភាព ផ្ដល់អំណាច និងឯករាជ្យភាពសម្រាប់ជនពិការ។ គោលដៅទាំងនេះត្រូវសម្រេចបាន តាមរយៈការពង្រឹង និងការលើកទឹកចិត្តឲ្យធ្វើការការជ្រើសរើស និងប្រើសិទ្ធិផ្ទាល់ខ្លួន ដើម្បីឲ្យបានជោគជ័យ ឬបរាជ័យក្នុងការស្វែងរកឯករាជ្យភាព និងការងារ ក្នុងសហគមន៍។**

**MRC ផ្ដល់សេវាគ្រប់យ៉ាងដល់ជនពិការ ដែលបង្កើនគុណភាពនៃជីវិត និងមានសេដ្ឋកិច្ចគ្រប់គ្រាន់សម្រាប់ខ្លួនជាអតិបរមា នៅក្នុងសហគមន៍។**

4

## ការរស់នៅក្នុងសហគមន៍

## ការងារ

## លក្ខណៈសម្បត្តិទទួលអត្ថប្រយោជន៍ភាពពិការ

## បុគ្គលិក MRC ពិនិត្យធនធានដែលមានទាំងអស់

មានបុគ្គលិកដែលមានសមត្ថភាពជាច្រើននាក់ នៅក្នុង MRC ហើយយើងក៏មានដៃគូជាច្រើននាក់ ជួយជ្រោមជ្រែងផងដែរ។ យើងបានក្លាយជាអ្នកជំនាញ ក្នុងការធ្វើការរួមគ្នាជា "MRC តែមួយ" ដើម្បីរកវិធីដែលយើងអាចធ្វើឲ្យលោកអ្នកទទួលបានជំនួយដែលលោកអ្នកត្រូវការ។

5

## គោលដៅ និងកិច្ចការត្រូវបានបង្កើតឡើង

លោកអ្នកនឹងក្លាយជាសមាជិកនៃក្រុម ចាប់ពីថ្ងៃទីមួយ។ ផែនការដែលយើងបង្កើតឡើងជាមួយលោកអ្នក នឹងដាក់ចេញជំហានជាក់ស្តែង និងច្បាស់លាស់។ វានឹងជាផែនការរបស់លោកអ្នក ហើយយើងនឹងធ្វើឲ្យវាដំណើរការ។

www.mass.gov/mrc

1-800-245-6543

(ទូរស័ព្ទឥតគិតថ្លៃតែក្នុងរដ្ឋ MA មួយគត់)

## 6A

## MRC នឹងនាំមកនូវធនធានផ្ទៃក្នុងសមរម្យទាំងអស់

ខណៈពេលដែលយើងបង្កើតក្រុមដែលអាចជួយលោកអ្នកឲ្យបានប្រសើរបំផុត យើងក៏ពិនិត្យមើលលក្ខណៈសម្បត្តិទទួលការបណ្តុះបណ្តាលអាជីវកម្ម និងការថែទាំសុខភាព ដើម្បីឲ្យដឹងថាតើលោកអ្នកមានលក្ខណៈសម្បត្តិទទួលអត្ថប្រយោជន៍ពី Social Security Administration ដែរឬទេ។ អត្ថប្រយោជន៍ទាំងនេះជួយជនពិការជាច្រើននាក់ឲ្យជួយខ្លួនឯង ខណៈពេលដែលពួកគេធ្វើការរួមគ្នាឆ្ពោះទៅរកគោលដៅរបស់គេ។

## 6B

## ដៃគូ MRC នឹងផ្តល់សេវាកម្មបន្ថែម

ដោយសារលោកអ្នកសិក្សាជំនាញថ្មី និងបណ្តុះបណ្តាលសមត្ថភាពថ្មី លោកអ្នកអាចយល់ឃើញថា លោកអ្នកត្រូវការជំនួយកាន់តែតិចទៅ។ៗពី MRC។ ភាពឯករាជ្យម្ចាស់ការរបស់លោកអ្នក ជាគោលដៅចម្បងរបស់យើង។ ចូរសម្រេចវាទាំងអស់គ្នា។

## 7

## អ្នកប្រើប្រាស់ឆ្ពោះទៅគោលដៅ

បន្តនៅផ្នែកខាងក្រោយ

MRC

គណៈកម្មការស្តារសម្បទា នៃរដ្ឋ Massachusetts

ខិត្តប័ណ្ណនេះមានក្នុងទម្រង់ផ្សេងទៀត តាមការស្នើសុំ។ សូមទាក់ទងនាយកផ្នែកទីផ្សាររបស់យើង តាមទូរស័ព្ទលេខ 617-204-3651 ឬ marketing@mrc.state.ma.us។ សូមអរគុណ។

**www.mass.gov/mrc**

**1-800-245-6543**
(ទូរស័ព្ទឥតគិតថ្លៃក្នុងរដ្ឋ MA មួយគត់)

**Commonwealth of Massachusetts**